**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងភាសាខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៦

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Aug-2016, 14:15
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ និងឧបសម្ព័ន្ធសម្ងាត់ចំនួនមួយ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវផ្ដល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (សំណុំរឿង ០០២/០២ (វគ្គជំនុំជម្រះទីបួន))**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

**ចៅក្រម និល ណុន ប្រធាន**

**ចៅក្រម យ៉ា សុខន**

**ចៅក្រម Jean-Marc LAVERGNE**

**ចៅក្រម យូ ឧត្តរា**

**ចៅក្រម Claudia FENZ**

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្ដី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្ដីផ្ដើម

1. អនុលោមតាមឯកសារ E315/1 និងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦[1] សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីកាលបរិច្ឆេទ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើស និងស្នើសម្រាប់សវនាការលើផលប៉ះពាល់ និងព្យសនកម្មទាក់ទងនឹងវគ្គសវនាការលើមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង (ហៅកាត់រួមគ្នាថា "វគ្គជំនុំជម្រះទីបួន") ។

## II. ច្បាប់ជាធរមាន

2. ផ្អែកទៅលើការអនុវត្តន៍ដែលមាននាពេលកន្លងមក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីទាំងអស់ថា បន្ទាប់ពីការធ្វើសវនាការបង្ហាញឯកសារគន្លឹះនៅចុងបញ្ចប់នៃវគ្គសវនាការនីមួយៗ អង្គជំនុំជម្រះនឹងរក្សាពេលពីរថ្ងៃ ដើម្បីស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពផលប៉ះពាល់ដែលពួកគាត់បានទទួលរងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[2]។

## III. ការពិភាក្សា

3. សហមេធាវីនាំមុខ ដោយសហការជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានពិនិត្យមើលយ៉ាងល្អិតល្អន់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានការជាប់ពាក់ព័ន្ធច្រើនទៅនឹងវគ្គជំនុំជម្រះទីបួន ហើយបានបង្កើតបញ្ជីឈ្មោះបុគ្គល ដែលសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងចង់ឲ្យពួកគេមកផ្ដល់សក្ខីកម្មនៅក្នុងអំឡុងសវនាការនាពេលខាងមុខនេះអំពីព្យសនកម្មដែលពួកគាត់បានទទួលរង។

4. សហមេធាវីនាំមុខស្នើសុំដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំមួយនាក់ ដែលនឹងត្រូវមកផ្ដល់សក្ខីកម្មដែលក្នុងនោះដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ជាជនរងគ្រោះមិនផ្ទាល់ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល

---

[1] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគីទាំងអស់ស្ដីពីសវនាការលើការបង្ហាញឯកសារគន្លឹះ និងសវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា ព័ត៌មានអំពី (១) សវនាការអំពីការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៧-៩។

ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបួននាក់ជាជនរងគ្រោះមិនផ្ទាល់ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ និង ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀតជាជនរងគ្រោះដោយផ្ទាល់ទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា។ គួរកត់សម្គាល់ផងដែរថា ដើមបណ្ដឹងរដ្ឋប្បវេណី ម្នាក់បានស្នើសុំផ្ដល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសល់ចំនួនប្រាំនាក់ផ្សេងទៀតត្រូវបានស្នើឲ្យមកផ្ដល់សក្ខីកម្មដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ សហមេធាវីនាំមុខសូមស្នើកាលបរិច្ឆេទសម្រាប់ការធ្វើសវនាការចំនួនពីរថ្ងៃនេះ ដោយសេចក្ដីលម្អិតនៃកាលបរិច្ឆេទនេះមានបញ្ជាក់ជូននៅក្នុងឧបសម្ព័ន្ធ ក ដែលភ្ជាប់មកជាមួយនឹងសំណើនេះ (ហៅកាត់ថា“កាលបរិច្ឆេទបណ្ដោះអាសន្ន និងដែលបានស្នើឡើង”)[3]។ កាលបរិច្ឆេទដែលបានស្នើ ឡើង ផ្អែកទៅលើការប៉ាន់ស្មានថា សវនាការក្នុងមួយថ្ងៃត្រូវការរយៈពេលប្រមាណបួនម៉ោងនិងម្ភៃប្រាំនាទី[4]។

5. សហមេធាវីនាំមុខបន្ថែមថា សវនាការទាំងនេះមានគោលបំណងផ្ដល់ឱកាសជូនដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីបង្ហាញពីការឈឺចាប់របស់ពួកគាត់ក្នុងនាមជាជនរងគ្រោះ និងផលប៉ះពាល់នៃព្យសនកម្មដែលពួកគាត់បានទទួលរងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដោយមិនអាចជៀសវាងបាន ព្យសនកម្ម និងការឈឺចាប់ដែលបានទទួលរងនៅក្នុងអំឡុងពេលនោះ ក៏ត្រូវជាប់ពាក់ព័ន្ធផងដែរទៅនឹងអង្គហេតុនានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយដែលនឹងត្រូវពិពណ៌នានៅក្នុងអំឡុងពេលសវនាការនេះផងដែរ។

6. សហមេធាវីនាំមុខយល់ឃើញថា ប្រសិនបើអង្គហេតុទាំងនេះត្រូវបានភាគីដទៃទៀតជំទាស់តវ៉ា នោះនឹងត្រូវមានការផ្ដល់ពេលវេលាសមស្របដើម្បីឲ្យភាគីធ្វើការសួរដេញដោល ដោយត្រូវគិតពីផលប្រយោជន៍ របស់អង្គជំនុំជម្រះនៅក្នុងការស្វែងរកការពិត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់។ ទន្ទឹមគ្នានេះដែរ ដើម្បីឲ្យសវនាការនេះនៅតែមានភាពជាប់ពាក់ព័ន្ធនោះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែមានលទ្ធភាពបញ្ចប់សក្ខីកម្មអំពីព្យសនកម្មរបស់ពួកគាត់ឲ្យបានពេញលេញនៅក្នុងរយៈពេលដែលបានផ្ដល់ទៅឲ្យពួកគាត់នោះ ហើយពេលវេលានេះមិនត្រូវបានប៉ះពាល់ដោយការជំទាស់នានារបស់ភាគីដែលអាចកើតមាននោះឡើយ។

---

[3] ឧបសម្ព័ន្ធ ក កាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណី។

[4] រយៈពេលបួនម៉ោងដែលត្រូវបានស្នើឡើងសម្រាប់ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី មិនរាប់បញ្ចូលរយៈពេលឈប់សម្រាកពីរដងជាធម្មតានោះឡើយ។

7. ដោយកត់សម្គាល់អំពីទម្លាប់កន្លងមករបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះសាលាដំបូងមិនដែលផ្តល់ពេលវេលាបន្ថែមទៀតដល់ភាគីដទៃទៀតក្នុងការតាំងសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីនោះ[5] សហមេធាវីនាំមុខបានរៀបចំផែនការដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងសវនាការលើផលប៉ះពាល់សម្រាប់ផ្នែកជំនុំជម្រះទីពីរ និងទីបីផងដែរ[6]។

8. ជាចុងក្រោយ សហមេធាវីនាំមុខស្នើសុំឱ្យទទួលយកជាឯកសារភស្តុតាងនូវឯកសារខាងក្រោមដែលជាចម្លើយមុនៗរបស់សាក្សីដែលត្រូវបានកោះហៅដោយអង្គជំនុំជម្រះ យោងតាមវិធាន ៨៣(៣) និងវិធាន៨៣(៤)[7] ដើម្បីជាប្រយោជន៍ក្នុងការស្វែងរកការពិត ដែលការសក្ខីកម្មទាំងនេះអាចអនុញ្ញាតឱ្យភាគី ក៏ដូចជាអង្គជំនុំជម្រះមានមូលដ្ឋានធ្វើការវាយតម្លៃពេញលេញលើសក្ខីកម្មដែលផ្តល់ដោយពួកគេ។ ឯកសារទាំងនោះរួមមាន៖

(i) D22/2732 ទំរង់បែបបទព័ត៌មានជនរងគ្រោះ 09-VU-01527[8]

(ii) D22/289a ទំរង់បែបបទព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[9]

---

[5] *សូមមើល* សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគីទាំងអស់ ស្តីពីសវនាការអំពីឯកសារគន្លឹះ និងសវនាការលើការថ្លែងពីការឈឺចាប់ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥។

[6] *សូមមើល* ឧបសម្ព័ន្ធ I៖ កាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី (វគ្គជំនុំជម្រះទីពីរ), ឯកសារ **E315/1/3.1** ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៥។ *សូមមើលផងដែរ* បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការ លើការថ្លែងពីការឈឺចាប់ ទាក់ទិននឹងវគ្គជំនុំជម្រះទីពីរ របស់សហមេធាវីនាំមុខ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់), ឯកសារ **E315/1/3** ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៥ *និងសូមមើល* សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខី-កម្មនៅក្នុងកំឡុងពេលសវនាការលើព្យសនកម្មដែលបានទទួល (ផ្នែកជំនុំជម្រះទី៣) និងសំណើអនុលោមតាមវិធាន៨៧(៤) (ដោយមានឧបសម្ព័ន្ធសម្ងាត់) ឯកសារ **E315/1/4** ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦។

[7] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុងសុំឱ្យទទួលយកជាឯកសារភស្តុតាងនូវឯកសារចំនួនពីរពាក់ព័ន្ធនឹងសាក្សីដែលមានរហស្សនាម 2-TCW-850, ឯកសារ **E417/1** ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ កថាខណ្ឌ២។ សូមមើល សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយអនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង និងសុំឱ្យកោះហៅសាក្សីបន្ថែមចំនួនបួននាក់ទៀតសម្រាប់វគ្គនានាខាងមុខនៃសំណុំរឿង០០២/០២ ,ឯកសារ **E319/36/2** ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ កថាខណ្ឌ១៥។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់ឯកសាររបស់សហព្រះរាជអាជ្ញា,ឯកសារ **E363/3** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ២៥។

[8] KH ERN 00555871-00555880។ ការបកប្រែ (ភាសាខ្មែរ-បារាំង និងភាសាខ្មែរ-អង់គ្លេស)បានស្នើសុំ។

## IV. សំណើ

9. ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ សហមេធាវីនាំមុខសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងឯកភាពលើកាលបរិច្ឆេទបណ្ដោះអាសន្ន និងដែលបានស្នើឡើង និងសូមៈ

ក) កោះហៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ក និងធ្វើការស្ដាប់សក្ខីកម្មរបស់ពួកគេ ស្របតាម កាលបរិច្ឆេទបណ្ដោះអាសន្ន និងដែលបានស្នើឡើង

ខ) ទទួលយកឯកសារចំនួនពីរដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ៨ និង

គ) បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ធ្វើការត្រៀមរៀបចំសម្រាប់ការមកផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយ ដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ ក។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសារណានេះដោយក្ដីគោរព។

| កាលបរិច្ឆេទ | នាម និងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | [signature] |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | [signature] |

[9] KH ERN 00827035-00827035; EN ERN 00877327-00877330; FR ERN 00585894-00585896